**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
*****

# កិច្ចព្រមព្រៀង

## ស្តីអំពី
## ការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត
## រវាង
## ក្រុមហ៊ុន ឌីន លីង ហ្គាម៉ិន ឯ.ក
## និង
## សហជីពនិងតំណាងកម្មករនិយោជិត នៃក្រុមហ៊ុន ឌីន លីង

នៅថ្ងៃទី១៩ខែកក្កដាឆ្នាំ២០២៣វេលាម៉ោង១៥និង០០នាទីនៅការិយាល័យក្រុមហ៊ុនឌីនលីងហ្គាម៉ិនឯ.ក មានបើកកិច្ចប្រជុំស្តីពីការដាក់ព្យួរកិច្ចសន្យាការងាររបស់កម្មករនៃក្រុមហ៊ុនឌីនលីងហ្គាម៉ិន ឯ.កខាងមុខនេះ៖

**សមាភាពចូលរួមមាន៖**

-តំណាងក្រុមហ៊ុន ឌីន លីង ហ្គាម៉ិន ឯ.ក

-តំណាងសហជីពនិងតំណាងកម្មករ នៃក្រុមហ៊ុន ឌីន លីង ហ្គាម៉ិន ឯ.ក

## កិច្ចព្រមព្រៀងស្នើសុំព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងស្នើសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន១១៣៥នាក់(ស្រី១០៣៣នាក់)ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១១៣៥នាក់ (ស្រី១០៣៣នាក់) រយៈពេល៣៨ថ្ងៃ គឺគិតចាប់ពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០២៣ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ ត្រូវធ្វើឡើងរវាងកម្មករនិយោជិត និង និយោជក នៃក្រុមហ៊ុន ឌីន លីង ហ្គាម៉ិន ឯ.ក ដោយមានការឯកភាពពី ប្រតិភូបុគ្គលិកពេញសិទ្ធិទាំងអស់ យល់ព្រមអោយ កម្មករនិយោជិតស្នើសុំព្យួរកិច្ចសន្យាការងារ រយៈពេល៣៨ថ្ងៃ តាមសំណូមពររបស់ក្រុមហ៊ុនដោយគ្មានការបង្ខិតបង្ខំ។

សម្រាប់រោងចក្រ៖ ក្នុងរយៈពេលព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតម្នាក់ៗចំនួន៤៥ដុល្លារអាមេរិក ក្នុងនោះមាន៖

-ចំនួន ១៥ដុល្លារអាមេរិក សម្រាប់ថ្ងៃទី២៥ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣។

-ចំនួន ៣០ដុល្លារអាមេរិក សម្រាប់ថ្ងៃទី១ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣។

បញ្ជាក់ ៖ ប្រាក់ព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុននឹងបើកជូនកម្មករនិយោជិត នៅថ្ងៃទី២០ ខែកក្កដាឆ្នាំ២០២៣។

ភាគីទាំងអស់ បានអាននូវខ្លឹមសារ និង យល់ពីអត្ថន័យនៃកិច្ចព្រមព្រៀងយ៉ាងច្បាស់ ហើយបានយល់ព្រមស្ម័គ្រចិត្តផ្តិតមេដៃស្តាំលើកិច្ចព្រមព្រៀងនេះ ដោយគ្មានការបង្ខិតបង្ខំពីជនណាឡើយ។

កិច្ចប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង១៦និង០០នាទី នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសយ៉ាងស្មោះត្រង់និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃពុធ ២កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
រាជធានីភ្នំពេញ.ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣

**តំណាងភាគីប្រតិភូបុគ្គលិកប្រចាំរោងចក្រ**
**ស្នាមមេដៃស្តាំ**

**តំណាងភាគីក្រុមហ៊ុន**
**ហត្ថលេខា និងត្រា**

ក្រុមហ៊ុន ឌីន លីង ហ្គាមិន ឯ.ក
DIN LING GARMENT CO.,LTD.
KINGDOM OF CAMBODIA